# បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ

# និង

# បទបញ្ជាផ្ទៃក្នុង

# ស្តីពី

# នីតិវិធីដែលត្រូវអនុវត្តនៅមុខ

# ក្រុមប្រឹក្សាធម្មនុញ្ញ

បោះពុម្ពផ្សាយដោយ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

ឆ្នាំ ២០០៣

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ជស-រកម-០៤៩៨-០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។
- បានឃើញអនុក្រឹត្យ លេខ ២១អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញអនុក្រឹត្យ លេខ ៨០អនក្រ-បក ចុះ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ១៩៩៨ ។

## សំរេច

## ជំពូកទី ១

## អំពីការប្រជុំលើកទី១របស់ក្រុមប្រឹក្សាធម្មនុញ្ញ

**ប្រការ ១ :**

មុនចូលកាន់តំណែងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើសច្ចាប្រណិធាន ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមិនបានធ្វើសច្ចាប្រណិធាន ដោយគ្មានមូលហេតុត្រឹមត្រូវក្នុងរយៈពេល ៧ ថ្ងៃ ក្រោយពីថ្ងៃចេញព្រះរាជក្រឹត្យតែងតាំងចុងក្រោយ អាចត្រូវទទួលវិន័យតាមវាក្យខ័ណ្ឌទី១ នៃមាត្រា ១០ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ ២ :**

ការកោះប្រជុំ និង ការដឹកនាំអង្គប្រជុំលើកទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើឡើងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានអាយុច្រើនជាងគេ ដែលបានធ្វើសច្ចាប្រណិធានហើយដែលមានវត្តមាន ដើម្បីជ្រើសតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ២
## អំពីបរិយាសម្បត្តិ នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

**ប្រការ ៣ :**

ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ និង អព្យាក្រឹតក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួន ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវប្រព្រឹត្តនូវអំពើដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ ឯករាជ្យភាព ឬ អព្យាក្រឹតភាពនៃមុខតំណែងរបស់ខ្លួនឡើយ ។

**ប្រការ ៤ :**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញក្នុងមុខតំណែងរបស់ខ្លួនមិនត្រូវ :

-កាន់កាប់នៅក្នុងគណបក្សណាមួយនូវមុខតំណែងទទួលខុសត្រូវ ឬដឹកនាំ ហើយជាទូទៅបំពេញនៅក្នុងនោះនូវសកម្មភាព ដែលមិនអាចស្រុះស្រួលគ្នាបានជាមួយបទប្បញ្ញត្តិនៃប្រការខាងលើ

-បណ្តោយឱ្យធ្វើនិទ្ទេសអំពីតួនាទីរបស់ខ្លួនជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញក្នុងឯកសារដែលអាចយកទៅបោះពុម្ពផ្សាយ និង ទាក់ទងទៅនឹងគ្រប់សកម្មភាពសាធារណៈ ឬ ឯកជន ។

**ប្រការ ៥ : ( កែប្រែ )**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវឱ្យប្រធានដឹងអំពីការផ្លាស់ប្តូរ ដែលអាចកើតឡើងក្នុងសកម្មភាពវិជ្ជាជីវៈ ឬ មុខរបររបស់ខ្លួនខាងក្រៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ ៦ :**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានបំណងសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ត្រូវសុំច្បាប់ឈប់ពិសេស ៧ ថ្ងៃ មុនការបើកយុទ្ធនាការឃោសនាបោះឆ្នោត ។ ការសុំនេះត្រូវបានការអនុញ្ញាត ។

**ប្រការ ៧ :**

ក្នុងករណីចាំបាច់ក្រុមប្រឹក្សាធម្មនុញ្ញនឹងវាយតម្លៃសមាជិករបស់ខ្លួនណា ដែលខ្វះខាតមិនបានបំពេញកាតព្វកិច្ចជាទូទៅ ជាពិសេសកាតព្វកិច្ចដែលមានចែងក្នុងប្រការ ៣ និង ប្រការ៤ នៃបទបញ្ជាផ្ទៃក្នុងនេះ ។

**ប្រការ ៨ :**

ក្នុងករណីដែលមានចែងក្នុងប្រការ ៧ ខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចដោយ បោះឆ្នោតសម្ងាត់យកតាមមតិភាគច្រើនដាច់ខាត នៃសមាជិកទាំងមូល (៥ សម្លេង យ៉ាងតិច ) ។

**ប្រការ ៩ : ( កែប្រែ )**

មន្ត្រីរាជការអគ្គលេខាធិការដ្ឋានត្រូវបំពេញការងារ តាមការកំណត់របស់អនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ និង ឈប់សំរាកការងារប្រចាំឆ្នាំ តាមអនុក្រឹត្យលេខ ៨០ អនក្រ-បក ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ លើកលែងតែក្នុងករណីមានការចាំបាច់បន្ទាន់ ។

## ជំពូកទី ៣

## អំពីរបៀបវារៈ

**ប្រការ ១០ :**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញរៀបចំគំរោងរបៀបវារៈនៃអង្គប្រជុំ ។ ក្នុងករណីដែលប្រធានមានធុរៈមិនអាចធ្វើបាន សមាជិកដែលមានអាយុច្រើនជាងគេដែលមានវត្តមានត្រូវរៀបចំរបៀបវារៈ ។

**ប្រការ ១១ :**

ក្នុងរបៀបវារៈមានសេចក្តីជាលំដាប់មុនក្រោយដូចជា :

១-បញ្ហាទាំងឡាយដែលក្រុមប្រឹក្សាធម្មនុញ្ញបានសំរេចទុកជាការប្រញាប់ ។

២-បញ្ហាទាំងឡាយដែលគេប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ៤

## អំពីរបៀបប្រជុំ

**ប្រការ ១២ :**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬដោយសមាជិកដែលមានអាយុច្រើនជាងគេ ដែលមានវត្តមាន បើប្រធានមានធុរៈមិនអាចធ្វើបាន។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិក ៧ រូបចូលរួម ។

អាសនានុក្រម នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំតាមលំដាប់អតីតភាព ។ ក្នុងករណីមានអតីតភាពស្មើគ្នា អាសនានុក្រមត្រូវរៀបចំតាមលំដាប់អាយុ ។

**ប្រការ ១៣ :**

ការកោះប្រជុំត្រូវធ្វើជាលិខិតអញ្ជើញភ្ជាប់ជាមួយគំរោងរបៀបវារៈ ហើយផ្ញើជូនសមាជិក យ៉ាងតិច ២ ថ្ងៃមុនថ្ងៃកំណត់ប្រជុំ លើកលែងក្នុងការប្រញាប់ ។

មុននឹងប្រជុំ គណៈលេខាធិការដែលមានអគ្គលេខាធិការឬអគ្គលេខាធិការរង រួមនិងលេខាធិការ២នាក់ទៀត ត្រូវពិនិត្យឱ្យច្បាស់ថា គ្មានមនុស្សដទៃនៅក្នុងសាលប្រជុំ បើក្រុមប្រឹក្សាធម្មនុញ្ញសំរេចថាត្រូវប្រជុំសម្ងាត់។

**ប្រការ ១៤ :**

មុននឹងចាប់ផ្តើមសម័យប្រជុំ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុម័តរបៀបវារៈនិងសមាសភាពលេខាធិការដែលត្រូវចូលរួមជាមួយអគ្គលេខាធិការ ឬ អគ្គលេខាធិការរង ។

ការប្រជុំត្រូវធ្វើតាមរបៀបវារៈ លើកលែងតែក្រុមប្រឹក្សាធម្មនុញ្ញសំរេចផ្សេងពីនេះ ។

ក្នុងពេលប្រជុំនីមួយៗ អគ្គលេខាធិការ ដោយមានលេខាធិការជួយផង ត្រូវស្រង់ឈ្មោះសមាជិកក្រុម-ប្រឹក្សាធម្មនុញ្ញដែលអវត្តមាន និង ធ្វើកំណត់ហេតុនៃអង្គប្រជុំ ។

ប្រការ ១៥ :

បើប្រធានយល់ឃើញថា ជាការមានប្រយោជន៍ ឬ ជាការចាំបាច់ ប្រធានអាចលើកពេលប្រជុំបាន ។

សមាជិកទាំងឡាយត្រូវទទួលការអនុញ្ញាតពីប្រធានជាមុនសិន ទើបនិយាយបានតាមលំដាប់មុនក្រោយ ដែលកត់ត្រាដោយគណៈលេខា ។ សមាជិកម្នាក់ៗនិយាយបាន១៥នាទីយ៉ាងច្រើន ក្នុងពេលអន្តរាគមន៍ម្តងៗ ។

ហាមមិនឱ្យនិយាយកាត់ពាក្យអ្នកដទៃ មិនឱ្យនិយាយវាយប្រហារលើបុគ្គល មិនឱ្យសំដែងអាការៈផ្សេងៗដែលនាំឱ្យខូចសណ្តាប់ធ្នាប់ ។

បើមានការជ្រួលច្របល់ក្នុងពេលប្រជុំ ហើយប្រធានហាមមិនស្តាប់នោះ ប្រធានអាចលើកពេលប្រជុំដោយដើរចេញពីសាលប្រជុំ ។

## ជំពូកទី ៥

## អំពីការបញ្ចេញមតិ

ប្រការ ១៦ :

ក្នុងបញ្ហាទាំងឡាយដែលត្រូវសំរេច ក្រុមប្រឹក្សាធម្មនុញ្ញអនុម័តដោយវិធីពីរយ៉ាងគឺ : ដោយលើកដៃ និងដោយបោះឆ្នោតសម្ងាត់ ។

ប្រការ ១៧ :

ក្នុងការអនុម័តទាំងពីរយ៉ាងនេះ គណៈលេខាធិការជាអ្នករាប់ចំនួនសមាជិក ដែលលើកដៃ ឬ រាប់សន្លឹកឆ្នោត ។ អគ្គលេខាធិការត្រូវរាយការណ៍ ជូនប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសលទ្ធផលជូនអង្គប្រជុំស្តាប់ ។

ប្រការ ១៨ :

ការអនុម័តទាំងឡាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវយកតាមមតិភាគច្រើនដាច់ខាត នៃសមាជិកទាំងមូល (៥សម្លេងយ៉ាងតិច) លើកលែងតែការអនុម័តបទបញ្ជាផ្ទៃក្នុងនិងការសំរេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវអនុម័តតាមមតិភាគច្រើន២ភាគ៣ ( ៦ សម្លេងយ៉ាងតិច ) ។

ប្រការ ១៩ :

ក្នុងការអនុម័តតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល បើចំនួនមតិយល់ព្រមនិងមតិមិនយល់ព្រមស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានឧត្តមានុភាព ។

ប្រការ ២០ :

សន្លឹកឆ្នោតសម្ងាត់មាន ៣ ពណ៌ :

-ពណ៌ " ខៀវ " សំគាល់ថាមិនយល់ព្រម

-ពណ៌ " ស " សំគាល់ថាព្រម

-ពណ៌ " ស ឆ្នូត ខៀវ " សំគាល់ថាអនុបវាទ

## ជំពូកទី ៦
## អំពីការខានមកប្រជុំ

**ប្រការ ២១ :**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនអាចអវត្តមាន ដោយគ្មានការអនុញ្ញាតពីប្រធានបានឡើយ ។ ប្រធានមានសិទ្ធិអនុញ្ញាតឱ្យសមាជិកឈប់ យ៉ាងយូរ ១៥ ថ្ងៃ។ ការឈប់លើសពី១៥ ថ្ងៃ ត្រូវសុំឱ្យអង្គប្រជុំក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រម ។

សមាជិកដែលមានជម្ងឺរយៈពេល ៥ ថ្ងៃជាប់ៗគ្នា ត្រូវមានសំបុត្រពេទ្យជាសំអាង ។

## ជំពូកទី ៧
## អំពីវិន័យ

**ប្រការ ២២ :**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមិនគោរពតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្តន្ទាទោសខាងបទវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

សមាជិកដែលមិនគោរពបទបញ្ជាផ្ទៃក្នុងត្រូវផ្តន្ទាទោសខាងបទវិន័យ ។

ទណ្ឌកម្មខាងវិន័យចំពោះក្រុមប្រឹក្សាធម្មនុញ្ញមាន :

១-ក្រើនរំឭកដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

២-ក្រើនរំឭកដោយចុះកំណត់ហេតុទៅលើកទី២ ដោយប្រធាន

៣-ស្តីបន្ទោសដោយធ្វើជាលាយលក្ខអក្សរ ។

**ប្រការ ២៣ :**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវក្រើនរំឭកសមាជិកដែលធ្វើខុសដដែល ក្នុងរយៈពេល៣០ថ្ងៃ ឬធ្វើឱ្យខូចសណ្តាប់ធ្នាប់ដោយល្មើសនឹងប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងនេះ ។

**ប្រការ ២៤ :**

សមាជិកណាដែលត្រូវក្រើនរំឭក៣ ដង ហើយនៅតែប្រព្រឹត្តខុស ត្រូវក្រើនរំឭកដោយមានចុះក្នុងកំណត់ហេតុ ។ វិន័យនេះនាំឱ្យមានការកាត់ប្រាក់បំណាច់ប្រចាំខែរបស់សមាជិកនោះចំនួន ១ ភាគ ៤ ។

**ប្រការ ២៥ :**

ត្រូវទទួលទណ្ឌកម្មវិន័យស្តីបន្ទោសសមាជិកណាដែល :

- នាំឱ្យជ្រួលច្របល់ក្នុងសាលប្រជុំ ឬ ក្រៅសាលប្រជុំ ឬ នាំអាទិ៍ឱ្យសមាជិកច្រើននាក់មិនចូលរួមធ្វើការក្នុងក្រុមប្រឹក្សាធម្មនុញ្ញ
- ប្រមាថមើលងាយ ឬ បង្កជម្លោះ ឬ គំរាមកំហែងសមាជិកដទៃទៀត ឬ ញុះញង់សមាជិកឯទៀតឱ្យប្រើហឹង្សា

-មើលងាយក្រុមប្រឹក្សាធម្មនុញ្ញ ឬ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
-ប្រមាថបើលងាយព្រះមហាក្សត្រ

វិន័យស្តីបន្ទោសនាំឱ្យមានការកាត់ប្រាក់បំណាច់ប្រចាំខែរបស់សមាជិកនោះចំនួន ៥០%រយៈពេលពីរខែ ។

**ប្រការ ២៦ :**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវទទួលវិន័យតាមប្រការ២៣ ប្រការ២៤ ប្រការ២៥ នៃបទបញ្ជាផ្ទៃក្នុងនេះ ក្រោយពីបានទទួលដំណឹងពីសំណុំរឿងផ្ទាល់ខ្លួន ត្រូវធ្វើការដោះសាក្នុងរយៈពេល ៥ ថ្ងៃ។ ផុតកំណត់នេះ ទោះបីសាមីខ្លួនបានធ្វើការដោះសា ឬ មិនដោះសាក្តី ក្រុមប្រឹក្សាធម្មនុញ្ញសំរេចដាក់វិន័យតាមមតិភាគច្រើនដូចមានចែងក្នុងប្រការ ១៨ និង ១៩ នៃបទបញ្ជានេះ ។

**ប្រការ ២៧ :**

ការដកសមាជិកណាមួយពីក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តតាមមាត្រា១០ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

ការសុំលាឈប់ពីតំណែងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញអាចប្រព្រឹត្តទៅបាន លុះត្រាតែសមាជិកនោះ បានជូនដំណឹងជាលាយលក្ខអក្សរមកក្រុមប្រឹក្សាធម្មនុញ្ញ និង ក្រោយពីស្ថាប័នមានសមត្ថកិច្ចតែងតាំង ឬ ជ្រើសតាំងបានតែងតាំង ឬ ជ្រើសតាំងសមាជិកថ្មីមកជំនួស ។

ក្នុងការអនុវត្តន៍ប្រការ ២៧ នេះ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែជូនដំណឹងភ្លាមទៅស្ថាប័ន ដែលមានសមត្ថកិច្ចតែងតាំង ឬ ជ្រើសតាំង ដើម្បីស្ថាប័នទាំងនោះតែងតាំង ឬ ជ្រើសតាំងសមាជិកថ្មីមកជំនួស ។

**ប្រការ ២៧ ស្ទួន:**

ការដកសមាជិកណាមួយពីក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមនេះ :

១-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជូនដំណឹងទៅសមាជិកដែលត្រូវដកចេញថាគេមានពេលវេលា១៤ថ្ងៃ ចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ដើម្បីធ្វើសារណាការពារខ្លួន ។

២-ផុតរយៈពេលនេះទោះបីសាមីខ្លួន មិនបានផ្ញើសារណាការពារខ្លួនមកក្រុមប្រឹក្សាធម្មនុញ្ញក៏ដោយ ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការ សំរេចលើករណីរឿងនេះបាន ។
ក្នុងពេលសវនាការ សាមីខ្លួនអាចអញ្ជើញមកការពារខ្លួននៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ឬ ចាត់តាំងតំណាង ឬមេធាវីមកការពារខ្លួនក៏បាន ។

## ជំពូកទី ៨

## អំពីសន្តិសុខក្នុងពេលប្រជុំ

**ប្រការ ២៨ :**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចរក្សាការពារមិនឱ្យមានភ័យន្តរាយខាងក្នុងក្តី ខាងក្រៅក្តី ដែលកើតមានដល់ក្រុមប្រឹក្សាធម្មនុញ្ញ។ ដើម្បីសំរេចកិច្ចការនេះ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញអាចប្រើកំលាំងនគរបាល ឬអន្តរាគមន៍ពីកំលាំងទ័ព ។

# ជំពូកទី ៩
# អំពីការស៊ើកែប្រែបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សាធម្មនុញ្ញ

**ប្រការ ២៩ :**

បទបញ្ជាផ្ទៃក្នុងនេះនឹងអាចកែប្រែបាន លុះត្រាតែមានសេចក្ដីស្នើសុំពីសមាជិកចំនួន ៣ នាក់ឡើងទៅ ហើយត្រូវបានអនុម័តយល់ព្រមដោយមតិភាគច្រើន ២ភាគ៣ នៃចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។

# ជំពូកទី ១០
# អំពីអវសានបញ្ញត្តិ

**ប្រការ ៣០ :**

បទបញ្ជាផ្ទៃក្នុងនេះត្រូវផ្សាយក្នុងរាជកិច្ច ។

**ប្រការ ៣១ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣២ :**

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានអនុម័តដោយមតិយល់ព្រម ២ ភាគ ៣ នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ( ៦ សម្លេងយ៉ាងតិច ) ហើយត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃ ដែលប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានចុះហត្ថលេខា ។

---

បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញចុះហត្ថលេខាដោយឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញថ្ងៃទ២៦ខែមិថុនា ឆ្នាំ១៩៩៨។ ក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ២៨.០៧.៩៨ និងតាមសេចក្ដីសំរេចចុះថ្ងៃទី ២៨ខែកក្កដា ឆ្នាំ ១៩៩៨ របស់ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចបន្ថែមប្រការ២៧ស្ទួន ហើយបន្ថែមពាក្យ " វិជ្ជាជីវៈ ឬ មុខរបរ " នៅប្រការ៥ និង "លុបពាក្យសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និង"នៅប្រការ ៩ ។

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុង

## ស្ដីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

បទបញ្ជា លេខ ២៤ កបធ ចុះថ្ងៃទី ០៨/០៧/៩៨ កែសំរួលដោយ

សេចក្ដីសំរេចលេខ ០៥/៩៩ កបធ.ប.សស.រ ចុះថ្ងៃទី ២១/០៥/៩៩

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦/១២/៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រម លេខ ជស/រកម/០៤៩៨/០៥ ចុះថ្ងៃទី ០៨/០៤/៩៨ ប្រកាសឱ្យប្រើច្បាប់បន្ថែមទៅលើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសអោយប្រើតាមព្រះរាជក្រម លេខ ជស-រកម-០៤៩៨-០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨

-បានឃើញបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៨

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញដែលបានធ្វើវិសោធនកម្ម នាថ្ងៃទី ២៨/០៧/៩៨

-បានឃើញអនុក្រឹត្យ លេខ ៤២ អនក្រ-បក ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្ដីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ ។

## សំរេច

### ជំពូកទី ១

### នីតិវិធីទាក់ទងនឹងការបកស្រាយរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់ និងសេចក្ដីសំរេច នៃស្ថាប័ននានារបស់រដ្ឋ

**ប្រការ ១ :**

អនុលោមតាមមាត្រា ១៥. ១៦. ១៧. ១៨ និងមាត្រា ១៩ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលសំណើពីព្រះមហាក្សត្រ ពីប្រធានរដ្ឋសភា ពីនាយករដ្ឋមន្ត្រី ពីតំណាងរាស្ត្រមួយភាគដប់ ពីតុលាការ ពីប្រជារាស្ត្រតាមរយៈប្រធានរដ្ឋសភា ឬ តំណាងរាស្ត្រមួយភាគដប់ ឬពីតុលាការកំពូល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចាត់អោយចុះបញ្ជីនៅអគ្គលេខាធិការដ្ឋាន ។

ប្រការ ២ :

រយៈពេលដោះស្រាយត្រូវចាប់រាប់តាំងពីថ្ងៃចុះបញ្ជីនេះ ហើយពេលវេលាដោះស្រាយត្រូវធ្វើតាមការកំណត់ក្នុងច្បាប់ ។

ប្រការ ៣ :

ក្រោយពេលចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនសំណើទាំងនោះទៅក្រុម នៃក្រុមប្រឹក្សា-ធម្មនុញ្ញ ដើម្បីពិនិត្យ ។ របាយការណ៍របស់ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវដាក់ជូនសម័យប្រជុំបឋមដើម្បីចុះសៀវភៅដាក់រឿងជំនុំជំរះ ។

ប្រការ ៤ :

ក្រុមនីមួយៗ នៃក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក៣ រូប ដែលមួយរូបជាសមាជិកតែងតាំងដោយព្រះ-មហាក្សត្រ មួយរូបជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង មួយរូបទៀតជាសមាជិកជ្រើសតាំងដោយរដ្ឋសភា ។

សមាជិកទាំងបីក្រុមនេះ ត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សា-ធម្មនុញ្ញ ។ សមាជិករាយការណ៍ត្រូវតែងតាំងដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

ប្រការ ៥ :

ក្នុងប្រតិបត្តិការងារសមាជិករាយការណ៍មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយគ្រាន់តែជូនពត៌មានទៅប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

ប្រការ ៦ :

ទោះក្នុងករណីណាក៏ដោយ សមាជិករាយការណ៍ត្រូវតែរាយការណ៍ជូនសម័យប្រជុំបឋម ដើម្បីចុះក្នុងសៀវភៅដាក់រឿងជំនុំជម្រះ។ របាយការណ៍នេះត្រូវដាក់ជូនអង្គប្រជុំពេញអង្គ ដើម្បីពិភាក្សានិងសំរេចជាស្ថាពរ។

ប្រការ ៧ :

ចំពោះគ្រប់សំណើអោយពិនិត្យទាំងអស់ខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចក្នុងពេលវេលាមួយ ដែលមានកំណត់ក្នុងច្បាប់និងតាមមតិភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល(៥សំលេងយ៉ាងតិច)។

## ជំពូកទី ២

## នីតិវិធីអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ប្រការ ៨ :

អនុលោមតាមមាត្រា២៥ ,២៦និងមាត្រា២៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ វិវាទកម្មដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវសំរេចដោយក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ ៩ :**

បុគ្គលណា ឬ គណបក្សនយោបាយណា ដែលមិនសុខចិត្តនឹងការមិនព្រមចុះបញ្ជីគណបក្សនយោបាយ ដោយក្រសួងមហាផ្ទៃ ឬ មិនសុខចិត្តនឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ មិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ត្រូវធ្វើពាក្យប្តឹងជាលាយលក្ខអក្សរជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ។ ពាក្យសុំនេះ ត្រូវបញ្ជាក់ :

១-ឈ្មោះបុគ្គល ឬឈ្មោះគណបក្សនយោបាយ ដែលជាអ្នកប្តឹងតវ៉ា

២-ឋានៈតាមផ្លូវច្បាប់របស់អ្នកប្តឹងតវ៉ា

៣-ឈ្មោះមណ្ឌលបោះឆ្នោត ដែលមានការប្តឹងតវ៉ា

៤-ឈ្មោះបុគ្គល ឬ គណបក្សនយោបាយ ដែលត្រូវបានគេប្រកាសថាជាប់ឆ្នោត ហើយដែលគេប្តឹងតវ៉ា

៥-គ្រប់ឯកសារ ឬ ភស្តុតាងសំរាប់គាំទ្រការសុំបដិសេធ

៦-អាស័យដ្ឋានអ្នកប្តឹងតវ៉ា

ក្រុមប្រឹក្សាធម្មនុញ្ញផ្អែកតាមឆន្ទានុសិទ្ធិរបស់ខ្លួនអាចទុកពេល ៥ ថ្ងៃ អោយបុគ្គល ឬ គណបក្ស នយោបាយ ដែលជាអ្នកប្តឹង ដើម្បីផ្តល់ភស្តុតាង ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចសំរេចមិនធ្វើការស៊ើបអង្កេតលើបណ្តឹងណាមួយ បើបណ្តឹងនោះមិនបំពេញលក្ខខណ្ឌកំណត់ក្នុងប្រការនេះ ។

**ប្រការ ១០ :**

ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តតាមប្រការ ៣. ៤. ៥ និងប្រការ៦ នៃបទបញ្ជានេះនិងមាត្រា៣០. ៣១. ៣២. ៣៣ និងមាត្រា ៣៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ ១១ :**

ក្រោយពីក្រុមនីមួយៗ បានពិភាក្សាចប់សព្វគ្រប់ហើយ ទោះបីការពិភាក្សានោះពុំបានចុះសម្រុងគ្នាក៏ដោយ ក៏ត្រូវធ្វើរបាយការណ៍មួយដាក់ជូនសម័យប្រជុំបឋម ដើម្បីចុះក្នុងសៀវភៅដាក់រឿងជំនុំជម្រះ ។ របាយការណ៍នេះត្រូវដាក់ជូនអង្គប្រជុំពេញអង្គ ដើម្បីពិភាក្សាសំរេច ។

**ប្រការ ១២ ( កែប្រែ ) :**

ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការជាសាធារណៈស្របតាមច្បាប់ដែលមាន ដើម្បីពិនិត្យនិងសំរេចក្នុងរយៈពេលដែលមានកំណត់ក្នុងច្បាប់ ។

**ប្រការ ១៣ :**

អង្គប្រជុំក្រុមប្រឹក្សាធម្មនុញ្ញដែលពិភាក្សាទៅលើរបាយការណ៍របស់ក្រុមត្រូវចាត់តាំងឱ្យធ្វើកំណត់ហេតុតាមករណីរឿងនីមួយៗ ។ ការសំរេចរបស់អង្គប្រជុំព្រមទាំងកំណត់ហេតុត្រូវចុះក្នុងសៀវភៅកំណត់ហេតុនៃជម្រះ។ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចតាមមតិភាគច្រើនដាច់ខាត នៃសមាជិកទាំងមូល ( ៥ សំលេងយ៉ាងតិច ) ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ។

**ប្រការ ១៤ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីបទបញ្ជានេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៥ :**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវទទួលអនុវត្តបទបញ្ជានេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

---

បទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ចុះហត្ថលេខាដោយឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ១៩៩៨ ។ សម័យប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី២០.០៥.៩៩ និង សេចក្តីសំរេចលេខ ០៥/៩៩ កបធ.ប.សស.រ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សំរេច កែចំណងជើងពី " បទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ " ទៅជា " បទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ " វិញ ។ បញ្ចូលក្នុងមូលបទនូវឃ្លា " បានឃើញព្រះរាជក្រម នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ព្រះរាជក្រម ជស/រកម/០៤៩៨/០៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់បន្ថែមទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ " ។ កែសំរួលប្រការ១២ ពី " ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបើកសវនាការជាសាធារណៈដើម្បីពិនិត្យនិងសំរេចក្នុងរយៈពេលដែលមានកំណត់ក្នុងច្បាប់ " ទៅជា " ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការជាសាធារណៈស្របតាមច្បាប់ដែលមាន ដើម្បីពិនិត្យនិងសំរេចក្នុងរយៈពេលដែលមានកំណត់ក្នុងច្បាប់ ។